**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣៣.សជណ.ប

# សារលិខិត
# ស្តីពី
# ការដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា
# និង
# កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់

***បងប្អូនជនរួមជាតិទាំងអស់ជាទីស្រលាញ់ និងជាទីនឹករលឹក!***

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សយ៉ាងក្រៃលែង និងសូមជម្រាបជូនជនរួមជាតិទាំងអស់ឱ្យបានជ្រាបថា ដើម្បីសម្រួលដល់ជីវភាពគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា ក៏ដូចជាគ្រោះទឹកជំនន់ធ្ងន់ធ្ងរតាមបណ្តាខេត្តមួយចំនួន, រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវវិធានការអន្តរាគមន៍គាំពារសង្គមពិសេស ដូចតទៅ៖

## ១. ការដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា

គ្រួសារងាយរងហានិភ័យ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយក្រសួងផែនការ ត្រូវទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ ចំនួន ៣លើក ក្នុងមួយលើកៗ ដូចខាងក្រោម៖

| ការឧបត្ថម្ភ | កម្រិតឧបត្ថម្ភតាមតំបន់ | | |
|---|---|---|---|
| | រាជធានីភ្នំពេញ | ទីប្រជុំជន | ជនបទ |
| **គ្រួសារ** | ៩៩ ៩០០ រៀល | ៨៧ ៣០០ រៀល | ៨១ ៣០០ រៀល |
| **សមាជិកគ្រួសារបន្ថែមក្នុងម្នាក់ៗ** | ២៨ ០០០ រៀល | ២៤ ០០០ រៀល | ២០ ០០០ រៀល |

កម្មវិធីនេះ ត្រូវអនុវត្ត **ក្នុងមួយគ្រានៃវិបត្តិ** ដែលការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភធ្វើឡើងចំនួន **៣លើក** តាមកាលបរិច្ឆេទ ដូចខាងក្រោម៖

**លើកទី១ ៖ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២**
**លើកទី២ ៖ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣**
**លើកទី៣ ៖ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។**

ក្នុងន័យនេះ ខ្ញុំសូមអញ្ជើញគ្រួសារងាយរងហានិភ័យដែលទទួលបាននូវការកំណត់អត្តសញ្ញាណ និងបានផ្ទៀងផ្ទាត់ឈ្មោះនៅឃុំ សង្កាត់ រួចរាល់ ទៅបើកប្រាក់ឧបត្ថម្ភនៅបញ្ជរវីងណាមួយ ដែលនៅជិតកន្លែងបងប្អូនរស់នៅ តាមកាលបរិច្ឆេទខាងលើ កុំបីខាន។

**២. ការដាក់ឱ្យដំណើរការកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់**

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានជួបប្រទះគ្រោះទឹកជំនន់ធ្ងន់ធ្ងរនាពេលកន្លងទៅ, រាជរដ្ឋាភិបាល យកចិត្តទុកដាក់លើជីវភាពរបស់គ្រួសារងាយរងហានិភ័យ ដោយដាក់ចេញបន្ថែមនូវអន្តរាគមន៍ជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរស់នៅក្នុងតំបន់ភូមិសាស្ត្រមួយចំនួនដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ **ក្នុងរាជធានី ខេត្តចំនួន ១៦** រួមមាន **រាជធានីភ្នំពេញ, ខេត្តកណ្តាល, តាកែវ, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពង់ធំ, កំពង់ចាម, ត្បូងឃ្មុំ, ខេត្តក្រចេះ, កំពង់ឆ្នាំង, ព្រៃវែង, កំពត, ស្វាយរៀង, និងឧត្តរមានជ័យ។**

គ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ នៅក្នុងតំបន់ភូមិសាស្ត្រនៃរាជធានី ខេត្តគោលដៅទាំង ១៦ ខាងលើ ត្រូវទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ តាមអត្រាដូចខាងក្រោម៖

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | កម្រិតប្រាក់ឧបត្ថម្ភ |
|---|---|---|
| ១ | គ្រួសារ | ៨០ ០០០ រៀល |
| ២ | សមាជិកគ្រួសារ ក្នុងម្នាក់ | ១៦ ០០០ រៀល |
| ៣ | កុមារអាយុពី០-៥ឆ្នាំ ក្នុងម្នាក់ | ១៦ ០០០ រៀល |
| ៤ | ជនមានពិការភាព ក្នុងម្នាក់ | ១៦ ០០០ រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើង ក្នុងម្នាក់ | ១៦ ០០០ រៀល |

កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ត្រូវអនុវត្តការបើកផ្តល់ជូនមួយខែម្តង សម្រាប់រយៈពេល **៣ ខែ ចាប់ពីខែធ្នូ ឆ្នាំ២០២២ តទៅ។** ក្នុងន័យនេះ ខ្ញុំសូមអញ្ជើញគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ដែលទទួលបាននូវការកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់ឈ្មោះនៅឃុំ សង្កាត់ រួចរាល់ ទៅបើកប្រាក់ឧបត្ថម្ភ **នៅរៀងរាល់សប្តាហ៍ទី២ នៃខែធ្នូ ឆ្នាំ២០២២, ខែមករា និងកុម្ភៈ ឆ្នាំ២០២៣** នៅតាមបញ្ជរវីងណាមួយ ដែលនៅជិតកន្លែងបងប្អូនរស់នៅ តាមកាលបរិច្ឆេទនីមួយៗ កុំបីខាន។

សូមជម្រាបជូនថា គ្រួសារដែលទទួលបានការឧបត្ថម្ភ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ មិនទទួលបានការឧបត្ថម្ភលើកទី១ ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា បន្ថែមនោះទេ។ ប៉ុន្តែគ្រួសារគោលដៅនេះ នឹងទទួលបានការឧបត្ថម្ភលើកទី២ និងទី៣ ដូចគ្រួសារងាយរងហានិភ័យដទៃទៀត នៅទូទាំងប្រទេស។

**៣. ការបន្តអនុវត្តយន្តការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ**

ឆ្លើយតបនឹងស្ថានភាពអូសបន្លាយនៃវិបត្តិកើតចេញពីសម្ពាធអតិផរណា ក៏ដូចជាដើម្បីផ្តល់នូវអន្តរាគមន៍ជំនួយសង្គមដល់គ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តយន្តការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ ជាបន្តទៀត។ ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋដែលមានជីវភាពលំបាក និងមានសមាជិកគ្រួសារមានភាពងាយរងគ្រោះ ១ ក្នុងចំណោម ៥ ដូចតទៅ៖ ជនមានពិការភាព, កុមារអាយុក្រោម ២ ឆ្នាំ, ជនចាស់ជរាមានអាយុចាប់ពី ៦០ ឆ្នាំឡើង, ស្ត្រីជាមេគ្រួសារ និងរស់នៅដោយគ្មានស្វាមី, គ្រួសារដែលមានសមាជិកសុទ្ធសឹងជាកុមារ និងមនុស្សចាស់ជរា (មិនមានសមាជិកគ្រួសារអាយុពី ១៩-៥៩ ឆ្នាំ) ទាក់ទងទៅកាន់ឃុំ សង្កាត់ដែលបងប្អូនរស់នៅ ដើម្បីទទួលបានការកំណត់អត្តសញ្ញាណ និងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ក្នុងអំឡុងពេលនៃវិបត្តិនេះ ឱ្យបានទាន់ពេល។

ដើម្បីធានាថាបងប្អូនប្រជាពលរដ្ឋងាយរងហានិភ័យ ក៏ដូចជាគ្រួសារក្រីក្រដែលកំពុងជួបការលំបាកពិតប្រាកដដោយសារឥទ្ធិពលនៃជំងឺកូវីដ-១៩ គ្រោះទឹកជំនន់ធ្ងន់ធ្ងរ និងសម្ពាធអតិផរណា, ខ្ញុំសូមចេញបញ្ជាយ៉ាងម៉ឺងម៉ាត់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ឱ្យបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការកំណត់អត្តសញ្ញាណ ក៏ដូចជាសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋគោលដៅ ឱ្យទទួលបានប្រាក់ឧបត្ថម្ភទាន់ពេល ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវយុត្តិធម៌ សមធម៌ សុចរិតភាព និងតម្លាភាព តាមការកំណត់របស់រាជរដ្ឋាភិបាល។

សម្រាប់ព័ត៌មានបន្ថែមអំពីការទទួលបានប្រាក់ឧបត្ថម្ភ សូមទាក់ទងអាជ្ញាធរឃុំ សង្កាត់ដែលនៅជិតផ្ទះបងប្អូន ឬមូលនិធិជាតិជំនួយសង្គម តាមរយៈទូរសព្ទលេខ ០១៥ ២១៩ ៨៨៨ ឬ ០៩២ ២១៩ ៨៨៨។

ថ្ងៃសៅរ៍ ១០ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ៩ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**